ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.)

ECONOMIC, SOCIAL AND CULTURAL COUNCIL (ECOSOCC)








# វិភាគស្ថានភាព

# សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ប្រចាំខែឧសភា ឆ្នាំ២០២០

# វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែឧសភា ឆ្នាំ២០២០*

របាយការណ៍វិភាគនេះជាលទ្ធផលនៃកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ.) លើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃអង្គារ ១០កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី យឹម ណុលឡា** ប្រធាន ក.ស.វ. ដែលសមាសភាពចូលរួមមានគណៈប្រតិបត្តិក.ស.វ. **ឯកឧត្តម នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អនុប្រធានក.ស.វ.និងជាប្រធានក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងអនុប្រធាន សមាជិក សមាជិកា និងជំនួយការនៃក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយការរៀបចំរបាយការណ៍នេះដោយពឹងផ្អែកលើមូលដ្ឋានព័ត៌មានទិន្នន័យពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ដែលជាធាតុចូលផ្សេងៗទៀតពីថ្នាក់ដឹកនាំ ទីប្រឹក្សាបច្ចេកទេស សមាជិក សមាជិកានៃ ក.ស.វ. ក្រសួងស្ថាប័នពាក់ព័ន្ធ និងមន្ត្រីអគ្គលេខាធិការដ្ឋាននៃក.ស.វ. តាមប្រព័ន្ធតេលេក្រាម។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់ (តារាង១)

➡ នាខែឧសភា ឆ្នាំ២០២០សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៦% ធៀបនឹងខែមុននិង កើនឡើង២,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន | +៤,៩% | ត្រីស្រស់ | +១០,៦% |
| ម្ហូបអាហារ | +៤,៧% | ផ្លែឈើ | +៥,៥% |
| ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | +៤,៦% | សាច់គោ | +៤,៤% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៤,២% | សាច់ជ្រូក | +៤,០% |
| ការសិក្សា | +៣,៥% | អង្ករ | +៣,២% |
| សំលៀកបំពាក់ និងស្បែកជើង | +២,៨% | សាច់មាន់ | +២,១% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +២,១% | បន្លែ | +១,៦% |
| គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | +១,៤% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៨–២០២០

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា P | កក្កដា P | សីហា P | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២០ | ដូចគ្នាឆ្នាំមុន | ៣,៦% | ២.៧% | ២,៨% | ១,៩% | ២,៤% | ៣,១% | ៣,០% | ២,៧% | | | | | |
| | មុន | ០,៥% | -០,១% | ០,៤% | -០,៦% | ០,៦% | ០,៣% | ០,៣% | ០,៣% | | | | | |
| ២០១៩ | ដូចគ្នាឆ្នាំមុន | ១,៥% | ២,០% | ២,២% | ២,១% | ២,០% | ១,៤% | ២,២% | ២,១% | ១,៧% | ១,៣% | ១,៨% | ៣,១% | ១,៩% |
| | មុន | -០,០២% | ០,៨% | ០,៣% | ០,៣% | ០,២% | -០,៤% | ០,៥% | ០,៦% | -០,០៣% | -០,១% | ០,១% | ០,៨% | |
| ២០១៨ | ដូចគ្នាឆ្នាំមុន | ២,០% | ២,៣% | ២,៣% | ២,៤% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ៣,១% | ២,៥% | ១,៦% | ២,៥% |
| | មុន | ០,១% | ០,៤% | ០,០៤% | ០,៥% | ០,៣% | ០,១% | -០,៣% | ០,៧% | ០,៣% | ០,៣% | -០,៣% | ០,១% | |

---

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឱ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឱ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

P: តួលេខខែមិថុនា ខែកក្កដា និងខែសីហា ២០២០ ជាតួលេខព្យាករណ៍ (តាមវិធីសាស្ត្រ DECOMPOSITION)

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់







តារាង១.៣. អត្រាប្តូរប្រាក់

| ប្រភេទ | ឧសភា ២០២០ | មេសា ២០២០ | ឧសភា ២០១៩ | ប្រភេទ | ឧសភា ២០២០ | មេសា ២០២០ | ឧសភា ២០១៩ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤១១៦៛/១$ | ៤០៩៩៛/១$ | ៤០៦២៛/១$ | **បាត/ដុល្លារ** | ៣១,៩បាត/១$ | ៣២,៤បាត/១$ | ៣១,៨បាត/១$ |
| **៛/បាត** | ១២៩៛/១បាត | ១២៦៛/១បាត | ១២៨៛/១បាត | **ដុង/ដុល្លារ** | ២៣២៨៨ដុង/១$ | ២៣៣០៧ដុង/១$ | ២៣៤១៥ដុង/១$ |
| **៛/ដុង** | ០,១៧៧៛/១ដុង | ០,១៧៦៛/១ដុង | ០,១៧៣៛/១ដុង | **យ៉ន់/ដុល្លារ** | ៧,១ យ៉ន់/១$ | ៧,១ យ៉ន់/១$ | ៦,៩ យ៉ន់/១$ |

## ២. ស្ថានភាពថវិកាជាតិ( តារាង២ )

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែឧសភា ឆ្នាំ២០២០ ថវិកាជាតិមានស្ថានភាពដូចខាងក្រោមៈ

**២.១. ចំណូលថវិកាជាតិ** ៈ អនុវត្តបាន ១ ៤៥៣,១ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៦៣,៣ លានដុល្លារ (*មធ្យមប្រចាំខែ ៩៦,១% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ១ ៤៥០,៥ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៣៦២,៦ លានដុល្លារ (*មធ្យមប្រចាំខែ ៩៦,៣% នៃផែនការ*) និងចំណូលមូលធនមានចំនួន ២,៧ ប៊ីលានរៀល ។

➢ ចំណូលថវិកាជាតិ ថយចុះ៤៧,២% ធៀបនឹងខែមុននិង ថយចុះ២៦,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្តៈ

✓ចំណូលសារពើពន្ធមានចំនួន ១ ៤៧៣,៣ ប៊ីលានរៀល ថយចុះ៤៦,៧% ធៀបនឹងខែមុននិង ថយចុះ២៦,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ អគ្គនាយកដ្ឋានពន្ធដារនិងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខរតនាគារជាតិចំណូលសារពើពន្ធមានចំនួន ១ ៣៦៧,៣ ប៊ីលានរៀល ថយចុះ៤៥,៨% ធៀបនឹងខែមុននិង ថយចុះ២៣,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន ៨៣,២ ប៊ីលានរៀល ថយចុះ៦,៦% ធៀបនឹងខែមុន និង ថយចុះ៥០,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៨–២០២០

(ប៊ីលានរៀល)




**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ**<br>(ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ**<br>(តាមតួលេខ រតនាគារជាតិ)<br>(ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :+២,៨% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (-៣៤,០%) | ➢អាជ្ញាបណ្ណក្នុងស្រុក : +១២៨,៦% | (-៣៤,៦%) |
| | | ➢ កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ: -៧៤,២% | (-៩២,៥%) |
| ➢ ចំណូលពន្ធដារ: -៦៤,៦% (អគ្គនាយកដ្ឋានពន្ធដារ) | (-១៧,៤%) | ➢សម្បទានរ៉ែ: +៣៩,៣% | (+៨៣,៤%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: +៦១២,៧% | (+២៥៨,៧%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១ ១៩៤,៦ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២៩៨,៦ លានដុល្លារ(*មធ្យមប្រចាំខែ ៦០,០% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១ ០៦០,៤ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២៦៥,១ លានដុល្លារ(*មធ្យមប្រចាំខែ ៨៦,៥% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១៣៤,២ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៣,៥ លានដុល្លារ (*មធ្យមប្រចាំខែ ២៣,៣% នៃផែនការ*) (តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិ ថយចុះ៣១,៥% ធៀបនឹងខែមុននិង ថយចុះ១៣,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្ត ថយចុះ២៩,១% ធៀបនឹងខែមុននិង ថយចុះ១២,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះ មានអតិរេកចំនួន ២៥៨,៦ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៦៤,៦ លានដុល្លារ (តួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៧–២០១៩

(ប៊ីលានរៀល)



# ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់ ( តារាង៣ )

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែឧសភា ឆ្នាំ២០២០ មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ $M_2$ មានចំនួន ១២២ ៤៧២,៤ ប៊ីលានរៀល មានការកើនឡើង២,០%ធៀបនឹងខែមុននិងកើនឡើង ១៣,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង$M_2$** ក្នុងខែនេះ ជារួមបណ្តាលមកពី ការកើនឡើងនៃ ប្រាក់បញ្ញើចរន្ត ២,៤% និងប្រាក់បញ្ញើផ្សេងទៀត ២,៣%។

➢ក្នុងខែនេះ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៦,៤% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៦% នៃរូបិយវត្ថុ$M_2$។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែឧសភា ឆ្នាំ២០២០




តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២០

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៥,៦% | ១៥,៧% | ១៦,៤% | ១៦,៥% | ១៦,៤% | | | | | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៤,៤% | ៨៤,៣% | ៨៣,៦% | ៨៣,៥% | ៨៣,៦% | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែឧសភា ២០២០: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




តារាង៣.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | ឧសភា ២០២០ | មេសា ២០២០ | ឧសភា ២០១៩ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ១១៣ ៤៣៥,៩<br>១២ ៦៤០,៤ | ១១៣ ៧២៧,៨<br>១២ ៥៨២,២ | ៩២ ៦៧០,៣<br>៥ ៧៨១,៣ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ២៩ ៨៤៣,៥ | ២៥ ២៩២,៦ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៤,៤% | ៤,៩% | ៥,១% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,៣% | ៣,៣% | ៣,៤% |

| | | | |
|---|---|---|---|
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១០,៦% | ៩,៧% | ១០,៣% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,០% | ៧,៨% | ៨,៥% |
| កម្ចីជារៀលនៅហត្ថកសិករ | ១៧,៦% | ១៨,០% | ១៨,០% |
| កម្ចីជារៀលនៅអម្រឹត | ១៨,០% | ១៨,០% | ១៨,០% |
| កម្ចីជារៀលនៅប្រាសាក់ | ១០,០% | ១៨,០% | ១៦,៩% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងថវិកាជាតិ (តារាង៤)

➡ក្នុងខែឧសភា ឆ្នាំ២០២០ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន ៦២,៥ ពាន់តោន កើនឡើង៥,០% ធៀបនឹងខែមុននិង កើនឡើង៧,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១ ០៧៥,៧ GWh មានការ កើនឡើង៦,២% ធៀបនឹងខែមុននិង កើនឡើង១២,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

- អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ២៩៦,២ GWh មានការ កើនឡើង៥,៦% ធៀបនឹងខែមុន និង កើនឡើង១១៨,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ៤០៧,០ GWh មានការ ថយចុះ១២,៥% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ១១,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន ២៧២,៣ GWh មានការ កើនឡើង៣៧,៥% ធៀបនឹងខែមុនប៉ុន្តែ ថយចុះ២៣,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ១០០,២ GWh មានការ កើនឡើង៤៤,៧% ធៀបនឹងខែមុន ប៉ុន្តែ ថយចុះ០,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

តារាង៤.១. ការចុះបញ្ជីរោងចក្រនិងឧស្សាហកម្មធុនតូច និងសិប្បកម្មនៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន — ឧសភា ២០២០* | *ចំនួន—មេសា ២០២០* | *ចំនួន—ឧសភា ២០១៩* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ២៦ | ២៤ | ៣៨ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៨៤៩ | ១ ៨២៣ | ១ ៦២១ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | | | ៤ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | | ២ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១ ០០៧,២ ពាន់ម² មានការ ថយចុះ៦,៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៣៥,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ៤៣៣,២ លានដុល្លារមានការ ថយចុះ៨,៩% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង១៨៤,៧% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម៉² — ឧសភា ២០២០ | ពាន់ម៉² —មេសា ២០២០ | ពាន់ម៉² —ឧសភា ២០១៩ |
|---|---|---|---|
| ▪ លំនៅឋាន | ២៨,៣ | ៥៣៧,៦ | ៧៣,៩ |
| ▪ ឧស្សាហកម្ម | ៤១៧,៨ | ១៤៦,៩ | ៦៧,៧ |
| ▪ពាណិជ្ជកម្ម | ២៨៤,២ | ២៨១,៤ | ១០១,៣ |
| ▪ ទេសចរណ៍ | ១២,៣ | ៧៦,៣ | ៥១,៧ |
| ▪ផ្សេងៗ | ០,០ | ០,០ | ០,០ |
| អនុញ្ញាតសរុប | ១ ០០៧,២ | ១ ០៧៧,៨ | ៣០០,៤ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺឧស្សាហកម្ម ៤១,៥% និងពាណិជ្ជកម្ម ២៨,២% នៃផ្ទៃក្រឡាសរុប។

## ➢សេវាកម្ម

តារាង៤.៣.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —ឧសភា ២០២០ | ចំនួន—មេសា ២០២០ | ចំនួន—ឧសភា ២០១៩ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៤០៨ | ៤១១ | ៦៧៤ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២៩ | ២៤ | ៧ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ៣៧១ | ៦២៣ | ៦១៣ |

## ➢ការងារ

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់— ឧសភា ២០២០ | នាក់— មេសា ២០២០ | នាក់— ឧសភា ២០១៩ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៨៨៣ | ១ ៨៧៤ | ១ ១២២ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ១៦ ៧៣៩ | ១៦ ២១៦ | ១២ ៥៦៩ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៦ ៧៣៩ | ១៤ ៧០៧ | ៧ ៨៧៨ |
| អ្នកទទួលបានការងារក្រៅប្រទេស | ០ | ១ ៥០៩ | ៤ ៦៩១ |

## ➢វិនិយោគ

តារាង៤.៥.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ឧសភា ២០២០ | មេសា ២០២០ | ឧសភា ២០១៩ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៥៣៧,១ | ៨៩៩,៧ | ៦៣,៧ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ២៧,៣ | ២៥,៦ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១១៩,៩ (៥,៧) | ៣៧៦,៧ (២៧,៨) | ៦៣,៧ (១៥,៩) |
| វិស័យទេសចរណ៍ | ១០៧,៩ | ៥៩,៣ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២៨២,១ | ៤៣៨,១ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២៧ | ៤៦ | ១១ |
| បង្កើតការងារ (ពាន់នាក់) | ១២,០ | ៣០,១ | ១១,៣ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន ៨៩១,០ ពាន់តោន មានការ កើនឡើង១៧,៤% ធៀបនឹងខែមុននិង កើនឡើង២,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ: ១៨,២% (-៩,១%) | ▪ កំពង់ផែកំពង់សោម: ១៧,០% (៨,៩%) |

## ➢ការចុះបញ្ជី និងចរាចរណ៍

តារាង៤.៧.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន –ឧសភា ២០២០ | ចំនួន–មេសា ២០២០ | ចំនួន–ឧសភា ២០១៩ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៣១,៦ | ២៣,០ | ៣៩,០ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ៦,៤ | ៦,១ | ៧,៨ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ២១៨ | ២៤៦ | ៣៤៨ |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៧,៤ | -៣៨,៦% | -៥៨,៤% |
| ក្នុងនោះទទួល | ២,៧ | -០,៣% | +២៨,៥% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៦,៤ | -៦១,៤% | -៩២,៤% |
| ក្នុងនោះទទួល | ៦,៤ | -៦១,៤% | -៨៧,៦% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១០៩០,៦ | +១,៣% | -១៣,៩% |
| ក្នុងនោះហៅចូល | ៤៤៧,៣ | -៥,២% | -៥,៤% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៣ ១៦០,២ | +៧,៨% | -៣៨,០% |
| ក្នុងនោះហៅចូល | ៣ ១២៩,៦ | +៩,២% | -៣៧,៩% |

## ➢ ធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ០,០ | ០,០% | ០,០% |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ១,៨ | +១៧១,៦% | -៩៨,៨% |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ៥,០ | +១២៤,៤% | -៦៨,៦% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ០,៤ | -៤៦,៣% | -៩៩,៦% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២០,១ | +១២,៤% | -៩៧,៥% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ០,៩ | -២១,១% | -៩៩,៥% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ១០,៥ | +១១៦,៤% | -៩៧,៨% |
| ✓ តាមផ្លូវអាកាស | ៧,២ | +៩១,៩% | -៩៧,៩% |
| ✓ តាមផ្លូវគោក និងទឹក | ៣,៣ | +២០០,៣% | -៩៧,៥% |

## ៥. ស្ថានភាពជញ្ជូនពាណិជ្ជកម្ម(តារាង៥)

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែឧសភា ឆ្នាំ២០២០ មានចំនួន ៥ ៦៦៣,៨ ប៊ីលានរៀល (ស្មើនឹង ១ ៤១៦,០ លានដុល្លារ ស.រ.អា.)ថយចុះ:០,៥% ធៀបនឹងខែមុននិងថយចុះ:២១,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៩,៨% | +៤,៩% | រថយន្តសរុប (ប៊ី.ល.រ) | +៦,១% | -៥០,៤% |
| ប្រេងម៉ាស៊ូត | +៣,២% | +៣,៤% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៤៩,០% | -២១,៨% |
| ឧស្ម័ន | +១១,១% | -៤,០% | នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម | +២០,៧% | +៤៣៨,៦% |
| អគ្គិសនីនាំចូលដោយEDC | +៣៧,៥% | -២៣,៧% | | | |
| ដែកសំណង់ | -២៤,៨% | -៥៤,៧% | | | |
| ស៊ីម៉ង់ត៍ | +៣០,៤% | -០,៩% | | | |

➡ **ការនាំចេញ** ខែឧសភា ឆ្នាំ២០២០ មានចំនួន **៥ ៨២១,២** ប៊ីលានរៀល ស្មើនឹង **១ ៤៥៥,៣** លានដុល្លារ ស.រ.អា. (១០២,៨% នៃការនាំចូល) មានការកើនឡើង៦៣,០% ធៀបនឹងខែមុន និងកើនឡើង១៩,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%ធៀបនឹងខែមុន* | *%ធៀបនឹងខែដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%ធៀបនឹងខែមុន* | *%ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | +៨៥,៥% | -៦២,៩% | ផលិតផលនេសាទ | +៥៧,៧% | -១៥,៥% |
| វាយនភណ្ឌនិងស្បែកជើង | -៩៩,៩% | -៩៩,៩% | កៅស៊ូ | +១២៧,៦% | +៥០,៤% |
| អង្ករ | -៣,៧% | +៨៨,១% | | | |

គម្រោងពហុកីឡាដ្ឋានជាតិមរតកតេជោ




ក្រុមការងាររៀបចំរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

អាសយដ្ឋានៈ អគារមិត្តភាព លេខ៤១ មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទៈ ០៨៥ ៧៧៧ ៩៤០ / ០១២ ៦៦២ ៣១៦ ទូរសារៈ ០២៣ ២២១ ៩៤០

Email: chyanit168@gmail.com / mamsarith@yahoo.com